# ស្តេចព្រៃ ពូជស្វា

១.　បុរីអស្ចារ្យ មហានគរ　　ធ្លាប់ល្បីលាន់ខ្ទរ លើភពផែន
　　វង្សក្សត្រវ័ន្ទ អង់អាចមែន　　ត្រួតត្រាដងដែន សីម៉ាជាតិ ។
២.　ធ្វើសឹកជាញជ័យ ដេញសត្រូវ　　ការពារទុកនៅ ប្រយោជន៍មាតុ
　　ប្រយុទ្ធយកឈាម ប្តូរនឹងជាតិ　　លោហិតព្រះមាតុ ពិតគុណថ្លៃ ។
៣.　ស្តេចចេញធ្វើសឹក ដឹកនាំទ័ព　　ពុំដែលនឹងធ្លាប់ គិតថាក្ស័យ
　　ទោះសោយវង្គត់ ក៏មានន័យ　　កេរ្តិ៍ព្រះនាមថ្លៃ ទុកសាវតា ។
៤.　ទីលានប្រយុទ្ធនិង សត្រូវ　　ស្តេចទុកដាននូវ ព្រះចេស្តា
　　ជាប្រាសទថ្ម ល្អអស្ចារ្យ　　ទុកអោយខេមរា បានយល់ដឹង ។
៥.　គម្ពីក្បួនច្បាប់ ដាប់ចារឆ្លាក់　　ទុកជាចំលាក់ ជាប់ព្រលឹង
　　នៅលើប្រាង្គប្រា ចារដំណឹង　　អោយកូនខ្មែរដឹង រៀនសូត្រតរ ។
៦.　តែអកុសល្យ ផលអាក្រក់　　ទឹកថ្លាប្រែល្អក់ ខ្មៅប្រែសរ
　　បុរីអស្ចារ្យ មហានគរ　　ធ្លាក់ព្រោះឈាមជ័រ ជនពាលា ។
៧.　វង្សក្សត្រវ័ន្ទ ដ៏អង់អាច　　បាត់បង់អំណាច ជារាជា
　　ពូជពាលចូលរោង ជ័យពិលា　　គ្រងរាជ្យសម្ភា ជាស្តេចព្រៃ ។
៨.　សប្បាយនិងស្រា បា បន ល្បែង　　ស្រើបស្រាលវង្វេង ជាមួយស្រី
　　មានស្នំស្នំឆ្វេង លេងពេញដៃ　　ប្រលែងយប់ថ្ងៃ គ្មានពេលលោះ ។
៩.　ស្តេចព្រៃវង្វេង និងតណ្ហា　　ស្រើបញ្ចុកស្រា បញ្ចុកដោះ
　　បង្ខើបលើក្រោម បញ្ចេញអស់　　អោយលេចរបស់ ថ្វាយស្តេចព្រៃ ។
១០.　បានស្រីនៅជិត និត្យបែបកាយ　　ស្តេចព្រៃលែងស្តាយ ស្រណោះដី
　　លែងគិតពីរាស្ត្រ ក្នុងបុរី　　គិតតែរឿងស្រី ស្នំសង្វាស់ ។

១១. ត្រពោគបាំងមុខ ទុកជាធំ ស្តេចព្រៃខ្លាចគ្រុម ជាងខ្លាចចាស់
ព្រហើនកោងកាច គ្មានកើ្តខ្មាស់ ទុកស្រីជាស្រះ ស្រែបុណ្យខ្លួន ។
១២. បំភ្លែរឿងខ្មៅ ទៅជាសរ អាក្រក់ជាល្អ លាក់បំពួន
ដើម្បីអំណាច បក្ខពួកខ្លួន ស្តេចព្រៃបិទពួន លាក់និងរាស្ត្រ ។
១៣. ស្តេចព្រៃពូកែ ដោយកល់ល្បិច ទាក់ទង កើត លិច មកពេញពាស
លុកលុយស្រុកខ្មែរ ធ្វើបាបរាស្ត្រ ស្តេចព្រៃជាម្ចាស់ ធ្វើមិនដឹង ។
១៤. យួនសៀមបៀមពិស ព្រួសពេញស្រុក ស្តេចព្រៃស្រម៉ុក ដេកសន្ទឹង
អោបស្រីឆ្វេងស្តាំ ធ្វើមិនដឹង ដូចគ្មានព្រលឹង គិតរឿងជាតិ ។
១៥. ស្តេចគ្មានកើ្តខ្មាស់ ក្រាស់កាមគុណ យួនដឹងជាមុន ទើបប្រើស្នៀត
បញ្ជូនស្រីស្អាត មកសូកសៀត ប្រើគ្រប់ល្បិចស្នៀត បោកយកដី ។
១៦. ដីកើ្តដំណែល ពីដូនតា ស្តេចព្រៃពូជស្វា គ្មានគិតអី
គិតតែសប្បាយ ដៃអោបស្រី យួនសៀមប្លន់ដី តាមតែចិត្ត ។
១៧. នេះព្រោះស្តេចព្រៃ ពូជល្ងង់ខ្លៅ មានខួរឈាមខ្មៅ គ្មានគំនិត
ពឹងយួនពឹងសៀម មិនចេះគិត ចុងក្រោយខ្មែរពិត ស្លាប់រាប់លាន ។
១៨. ស្តេចព្រៃកញ្ជះ សៀម ចិន យួន ប្រឹងលាក់ប្រឹងពួន ហើយមិនហ៊ាន
ទទួលយកខុស ជាមេរៀន បែជាព្រមាន សងសឹកខ្មែរ ។
១៩. ធ្វើបាបសំលាប់ រាស្ត្រខ្លួនឯង ស្តេចព្រៃសំញ៉ែង ថាពូកែ
ចំពោះបរទេស ឈ្លានពានខ្មែរ ស្តេចព្រៃដូចឆ្កែ បំរើគេ ។
២០. ស្តេចព្រៃចាយដី ដូចចាយប្រាក់ យកដីធ្វើផ្ទាក់ ទាក់ស្រីស្នេហ៍
នេះគឺសារជាតិ ស្តេចលែងកែ ស្តេចព្រៃស្រុកខ្មែរ ឆ្កែជាគ្នា......... ។

**ដោយៈ សួន សេរីរដ្ឋា**

**(ដែនដីសេរីភាព)**